# សេចក្ដីសង្ខេប

Draft

# សេចក្តីសង្ខេប

## ១. សេចក្តីផ្តើម

ស្របពេលជាមួយគ្នានេះដែរផែនការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២របស់រាជរដ្ឋាភិបាលបានជំរុញ និងលើកទឹកចិត្តអ្នកវិនិយោគទាំងក្នុងស្រុក និងក្រៅស្រុក ជាពិសេសវិនិយោគលើវិស័យធនធានរ៉ែក្នុងចំណោមវិស័យសំខាន់ៗដទៃទៀត ដើម្បីជំរុញការអភិវឌ្ឍន៍ប្រទេសអោយមានសន្ទុះលឿនថែមមួយកម្រិតទៀត។

ដោយផ្អែកលើលក្ខណ:អំណោយផលនានា ឱកាស និងឆ្លើយតបចំពោះតម្រូវការក្នុងការអភិវឌ្ឍន៍ប្រទេសជាតិក៏ដូចជាការអភិវឌ្ឍន៍ក្នុងតំបន់ ជាពិសេសដើម្បីចូលរួមចំណែកជួយរាជរដ្ឋាភិបាល សំរេចបាននូវទិសដៅដែលបានដាក់ចេញ ក្រុមហ៊ុន ភូ យ៉ាង (ខេមបូឌា) **PHU YANG (CAMBODIA) Co.,Ltd** បានពិនិត្យឃើញថាការវិនិយោគសំរាប់ការធ្វើអាជីវកម្មរ៉ែលោហៈ និងផែនការផលិតកម្ម ដែលជាការវិនិយោគមួយសមស្របបំផុតនៅលើស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ព្រោះការវិនិយោគនេះស្របជាមួយនឹងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក៏ដូចជាផែនការ និងគោលដៅដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចខេត្តផងដែរ។

ទន្ទឹមនឹងនេះដែរក្រុមហ៊ុនវិនិយោគបានសហការជាមួយនឹងក្រុមហ៊ុន **Green Environment Group Co.,Ltd** ដើម្បីធ្វើការសិក្សា និងចងក្រងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញក្នុងគោលបំណងកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន និងបង្កើនហេតុប៉ះពាល់បរិស្ថានវិជ្ជមាន។

## ២. ក្របខ័ណ្ឌច្បាប់

នៅក្នុងបរិបទថ្មីដែលប្រទេសជាតិមានសង្គ្រាមផងសន្តិភាពផង កម្ពុជាបានខិតខំចងក្រងនូវលិខិតបទដ្ឋាននានាបានយ៉ាងច្រើនសំរាប់យកមកអភិវឌ្ឍន៍ប្រទេសអោយក្លាយទៅជាប្រទេសនីតិរដ្ឋ។ លិខិតបទដ្ឋានច្បាប់ ដែលពាក់ព័ន្ធនឹងគំរោងវិនិយោគអាជីវកម្មរ៉ែលោហៈ និងការវាយតំលៃហេតុប៉ះពាល់បរិស្ថានរួមមានច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ជលផល ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ច្បាប់ភូមិបាល ច្បាប់ការងារ អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង និងប្រកាសស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ។

## ៣. ការពិពណ៌នាអំពីគម្រោង

ក្រុមហ៊ុន **ភូ យ៉ាង (ខេមបូឌា)** " PHU YANG (CAMBODIA) Co., Ltd. " បានស្នើសុំគម្រោងវិនិយោគធនធានរ៉ែលោហៈពីរាជរដ្ឋាភិបាល តាមរយៈឯកឧត្តមទេសរដ្ឋមន្ត្រីក្រសួងបរិស្ថាន លើទំហំផ្ទៃដីចំនួន ០៤ គីឡូម៉ែត្រក្រឡា ដែលការវិនិយោគនេះសំរាប់ធ្វើអាជីវកម្មរ៉ែលោហៈដែលបានស្នើសុំនេះ ស្ថិតនៅក្នុងភូមិសាស្ត្រតំបន់ភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។

ក្រុមហ៊ុនវិនិយោគនេះមានម្ចាស់ភាគហ៊ុនចំនួន ០៥រូបគឺ (១) លោក លីន លុន ជាប្រធានក្រុមប្រឹក្សាភិបាល (២) លោក ប៊ុន ចាន់នី ជាអភិបាល (៣) លោកស្រី តៅ រ៉ានី (៤) លោក អ៊ឹង ថៃអ៊ីតមិញ និង (៥) លោកស្រី CHUTHI PHUONG DUNG ដែលមានដើមទុនចុះបញ្ជីសរុបចំនួន ២០.០០០.០០០ រៀល (ម្ភៃលានរៀល)។

ធនធានរ៉ែផ្សេងៗទៀតដែលនៅជាមួយមាសក្នុងជម្រករ៉ែមាសភ្នំព្រីក រួមមានរ៉ែប្រាក់ ទង់ដែង សំណ និងរ៉ែសង្កសី ដែលនៅក្នុងនោះមានតែរ៉ែប្រាក់ និងទង់ដែងតែប៉ុណ្ណោះ ដែលមានផលប្រយោជន៍ពាណិជ្ជកម្ម។ សមាសធាតុទាំងពីរនេះត្រូវបានគណនានៅក្នុងរបាយការណ៍នេះផងដែរ។

ផែនការផលិតកម្ម: អាជីវកម្មរ៉ែមាសនៅតំបន់ភ្នំព្រីក ក្រុមហ៊ុនបានធ្វើការបែងចែកជា ២ ដំណាក់កាលគឺ:

-ដំណាក់កាលទី១ ការបកស្រទាប់ដីដែលនៅផ្នែកខាងលើចេញ ហើយស្រទាប់ដីនេះត្រូវបានដឹកជញ្ជូនដោយ ថេយន្តទៅគរទុកនៅក្រៅតំបន់អភិវឌ្ឍន៍ ហើយបរិមាណអាចម៍ដីនេះតិច ឬច្រើនគឺអាស្រ័យទៅនឹងកំរាល់ដីដែលត្រូវបកចេញ។

-ដំណាក់កាលទី២ គឺជាតំណាក់កាលនៃការធ្វើអាជីវកម្មរ៉ែមាសនៅតំបន់ភ្នំព្រីក ហើយដោយរ៉ែមាសភាគច្រើននៅតំបន់នេះជារ៉ែរបេះដាច់ ហេតុនេះតំណាក់នេះគឺពុំចាំបាច់ប្រើម៉ាស៊ីនខួង និងធ្វើការផ្ទុះនោះឡើយ គឺគ្រាន់តែប្រើអេស្កាវ៉ាទ័រចូកយករ៉ែរបេះដាច់នេះយកទៅចំរាញ់តែម្តងៗប៉ុន្តែបើស្រទាប់រ៉ែរបេះដាច់នេះអស់ហើយ ចូលទៅតំណាក់កាលដែលត្រូវជីកយករ៉ែមាសដែលនៅលាយឡំជាមួយ Sulfide Quartzនៃសិលាកំបោរនោះគឺ ក្រុមហ៊ុននឹងត្រូវប្រើបច្ចេកទេសក្នុងការខួង និងផ្ទុះដោយប្រើរ៉ែសេវប្រភេទ High Explosive (HITH)៕

យោងតាបលទ្ធផលនៃការសិក្សាស្រាវជ្រាវរ៉ែមាសនៅតំបន់ភ្នំព្រីកនេះ: ឃើញថាបរិមានដែលបានស្រាវជ្រាវឃើញមានបរិមាណចំនួន ៩៩២.១៤៥,២២t ដែលក្នុងនោះមានមាសសុទ្ធចំនួនប្រមាណ ៥.៩៤t និងរ៉ែដែលមានប្រយោជន៍ផ្សេងៗទៀត ដូចជាប្រាក់ (Ag) និងទង់ដែង (Cu)។ តាមបរិមាណរ៉ែមាសដែលបញ្ជាក់ជូនខាងលើនេះ ឃើញថា ក្រុមហ៊ុនមានគំរោងជីកយករ៉ែមាសដើម្បីធ្វើអាជីវកម្មក្នុងបរិមាណ ៤០០តោន/០១ថ្ងៃ ដូចនេះរយៈពេលនៃការធ្វើអាជីវកម្មត្រូវគិតតាមរូបមន្តខាងក្រោម:

៤០០ ton / ០១ថ្ងៃ x ៣០០ថ្ងៃ=១២០.០០០,០០ton /០១ឆ្នាំ (ដោយមិនគិតថ្ងៃធ្វើការចំនួន៣០០ថ្ងៃ/០១ឆ្នាំ)

ដូចនេះអាយុកាលនៃអណ្តូងរ៉ែគឺស្មើ: ៩៩២.១៤៥,២២ ton / ១២០.០០០,០០ ton = ៨.២៦ ឆ្នាំ

យោងតាមលទ្ធផលនៃការវិភាគឃើញថាអត្រានៃ Gold exstraction មានចំនួន ៩០ភាគរយ និង Gold Recovery ចំនួន ៩៥ភាគរយ ដូចនេះយើងអាចគណនាតាមរូបមន្តខាងក្រោម:

៤០០ ton x ៣០០ day x ៨.៦៤g/t x ០.៩០ x ០.៩៥ = ៨៨៦.៤៦៤g

ជាមួយគ្នានេះតំលៃមាសនៅលើទីផ្សារ គឺស្មើ ១.២០០,០០US$/oz (១oz = ៣១.១០៤g) ដូចនេះកំរៃដែលទទួលបានអាជីវកម្មរ៉ែមាសក្នុងរយៈពេល០១ឆ្នាំគឺ:

៨៨៦.៤៦៤ g/៣១.១០៤ x ១.២០០,០០US$= ៣៤.២០០.០០០,០០US$ ។

ខ្សែសង្វាក់ផលិតកម្មនៃការជីកយករ៉ែរួមមាន: (១) វិធីសាស្ត្រនៃការជីកយករ៉ែ (ការកាយចេញគម្របដីលើ ការខួងរន្ធ និងការបំផ្ទុះថ្ម ការផ្ទុកថ្មរ៉ែ និងការដឹកជញ្ជូនរ៉ែ) (២) ការធ្វើប្រព្រឹត្តកម្មរ៉ែ (ការកិនបំបែករ៉ែ ការចម្រាញ់រ៉ែ និងការបន្សុទ្ធរ៉ែមាស: វិធីចម្រាញ់រ៉ែមាសតាមដង់ស៊ីតេ និងវិធីចម្រាញ់រ៉ែមាសដោយវិធីត្រាំក្នុងសូលុយស្យុងស៊ីយ៉ានួ)។

ការស្តុកទុកសំណល់: សំណល់ពីការធ្វើអាជីវកម្ម មានពីរប្រភេទ គឺសំណល់ថ្មមិនមានផ្ទុកសារធាតុរ៉ែដែលជីកយកចេញពីអណ្តូងរ៉ែ និងសំណល់ពីអាងចម្រាញ់រ៉ែដែលមានផ្ទុកទៅសារធាតុពុល។ សំណល់ទាំងពីរប្រភេទនេះត្រូវស្តុកទុកយ៉ាងមាំមួនដើម្បីធានាមិនអោយមានការខូចខាតឬបំពុលដល់បរិស្ថានជុំវិញ៕

ការប្រើប្រាស់ទឹក: តំបន់ជីកយករ៉ែ ជាតំបន់ដែលខ្សត់ប្រភពទឹកលើដី។ ជងអូរតូចៗមួយចំនួនក្នុងតំបន់គម្រោងមានទឹក តែក្នុងរដូវវស្សាហើយមិនសូវមានទឹកនៅរដូវប្រាំង។ ផ្ទុយទៅវិញប្រភពទឹកក្រោមដីមានច្រើនដោយសារតែតំបន់នេះជាតំបន់ថ្មកំបោរ។ ទឹកពីប្រភពទឹកក្រោមដីនឹងត្រូវបូមយកមកប្រើប្រាស់សម្រាប់ដំណើរការអាជីវកម្មរ៉ែនៅក្នុងតំបន់នេះ។ ទឹកនេះត្រូវបានទៅប្រើប្រាស់មួយផ្នែកធំសម្រាប់ការធ្វើប្រព្រឹត្តិកម្មរ៉ែដូចជា នៅក្នុងការកិនរ៉ែ ការបង្ហូររ៉ែ ការទាក់រ៉ែ និងទឹកដែលប្រើសម្រាប់ការត្រាំរ៉ែជាដើម។

ក្រុមហ៊ុនគ្រោងខួងអណ្តូងទឹកពីរកន្លែង នៅរោងចក្រជ្រើសរើសរ៉ែ ដោយប្រើម៉ាស៊ីនបូមទឹក បូមផ្ទាល់ទៅអាងទឹកមានទីតាំងខ្ពស់ ដើម្បីផ្គត់ផ្គង់ទឹកទៅកន្លែងប្រើទឹក ទឹកសំណល់បន្ទាប់ពីការរងហើយរបស់ឃ្លាំងផ្ទុករ៉ែមិនត្រូវការ (Refuse) និងប្រើប្រាស់ ឡើងវិញ (វិលជុំ)។

ការប្រើប្រាស់ថាមពលអគ្គិសនី: ក្រុមហ៊ុនគ្រោងបង្កើតក្រុមម៉ាស៊ីនភ្លើង រៀបចំបំរុងទុកខ្លួនឯងសម្រាប់រោងចក្រជ្រើសរើសរ៉ែ អាចបំពេញនូវតំរូវការក្នុងការ ជ្រើសរើសអគ្គិសនីសម្រាប់វិស្វកម្មនេះ។

ការប្រើប្រាស់ប្រេងឥន្ធនៈ: ប្រេងឥន្ធនៈមួយភាគធំ ត្រូវបានប្រើប្រាស់សម្រាប់គ្រឿងចក្រខួង និងបំផ្ទុះរ៉ែ និងគ្រឿងចក្រកាយ ផ្ទុក និងដឹកជញ្ជូនរ៉ែ និងមួយផ្នែកទៀតសម្រាប់ការចាក់ម៉ាស៊ីនភ្លើង និងយានយន្តផ្សេងទៀត។ ការប៉ាន់ស្មានបរិមាណប្រេងដែលប្រើប្រាស់ក្នុងមួយឆ្នាំមានប្រមាណ ៦០០,០០០លីត្រ។ ប្រេងឥន្ធនៈនេះមានទាំងប្រេងសាំង ប្រេងម៉ាស៊ូត និងប្រេងម៉ាស៊ីន។ ស្ថានីយប្រេងតូចមួយ និងត្រូវសាងសង់ដើម្បីរក្សាទុកប្រេងសម្រាប់ប្រើប្រាស់នៅក្នុងការដ្ឋាន៕

## ៤. ការពិពណ៌នាអំពីធនធានបរិស្ថានដែលមានស្រាប់

ធនធានបរិស្ថានដែលមានស្រាប់នៅក្នុងតំបន់គឺសំដៅទៅលើអ្វីៗដែលកើតមានឡើងរួចមកហើយ ពោលគឺជាធនធានដែលកើតមានដោយខ្លួនឯង និងធនធានកើតឡើងដោយសារសកម្មភាព មនុស្សជាអ្នក បង្កើតរួមមានធនធានធម្មជាតិ និងធនធានសេដ្ឋកិច្ច-សង្គម។

នៅក្នុងតំបន់ដីស្នើ សុំនេះជាតំបន់ជំរាលទាប ដែលមានរយៈកំពស់ជាមធ្យម ៣១៦,៧៨ ម៉ែត្រធៀប នឹងនីវ៉ូទឹកសមុទ្រ។ ការប្រែប្រួល នៃរយៈកំពស់ក្នុងតំបន់ដីស្នើសុំគឺមានស្ថានភាពទាបបំផុត នៅជាប់ព្រំប្រទល់ប៉ែក លិចឈាងខាងជើងនៃតំរោង ដែលមានកំពស់អប្បបរមា ០ម៉ែត្រ និងមានសភាពខ្ពស់ខ្លាំងបំផុតនៅប៉ែកខាងត្បូងឈាងខាងលិចនៅជាប់ព្រំប្រទល់តំរោង ដែលមានរយៈកំពស់អតិបរមាដល់ ៥៦០ម៉ែត្រធៀបនឹងនីវ៉ូទឹកសមុទ្រ។

តំបន់ដែលមានទីជំរាលខ្លាំងភាគច្រើនស្ថិតនៅភាគខាងត្បូងក្នុងតំបន់គម្រោង។កំរិតជំរាលមានការប្រែប្រួលពី ០-៩០ដឺក្រេ ដោយមានទីជំរាលមធ្យមគឺ ១២,២៩ដឺក្រេ។

តាមប្រភពទិន្នន័យ ស្តីពីសីតុណ្ហភាពរយៈពេល ០៧ឆ្នាំចុងក្រោយ របស់នាយកដ្ឋានឧតុនិយមនៃក្រសួងធនធានទឹក និងឧតុនិយម ត្រង់ស្ថានីយ៍ខេត្តបាត់ដំបងបានបង្ហាញថា:

- សីតុណ្ហភាពមធ្យមអតិបរមាប្រចាំឆ្នាំមានកំរិត៣០,៥°C

- សីតុណ្ហភាពមធ្យមអប្បបរមាប្រចាំឆ្នាំមានកំរិត ២៦,៣ °C

ស្របតាមការវិភាគលើសំណាកទឹកទាំង២សំណាកខាងលើ យើងបានពិសោធន៍ទៅលើប៉ារ៉ាម៉ែត្រចំនួន ១៤ ផ្សេងពីគ្នា ដែលរួមមានដូចជា៖ pH, Turbidity, Total Suspended Solid (TSS), Total Dissolved Solid (TDS), Biochemical Oxygen Demand (BOD), Total Nitrogen (TN), Total Coliform, Oil and Grease, Calcium (Ca), Magnesium (Mg), Lead (Pb), Cadmium (Cd), Arsenic (As), Mercury (Hg) ដែលប៉ារ៉ាម៉ែត្រទាំងនេះជាប៉ារ៉ាម៉ែត្រដែលសំខាន់សំរាប់ធ្វើការអភិរក្សជីវៈចំរុះ និងកំរិតស្តង់ដាគុណភាពទឹកបរិភោគ។

តំបន់ស្នើសុំនេះមានស្ថានភាពគំរបព្រៃចំនួន ២ប្រភេទគឺ គំរបព្រៃស្រោង មានផ្ទៃដីទំហំ ៩៩ហិកតា និងផ្ទៃដីគ្មានគំរបព្រៃ មានផ្ទៃដីទំហំ ៣០១ហិកតា (រដ្ឋបាលព្រៃឈើ ឆ្នាំ២០០២)។

តាមការចុះសិក្សាអង្កេតជាក់ស្តែងពី ស្ថានភាពនៅក្នុងតំបន់គំរោងមានតែដីចំការ និងដីលំនៅស្ថានរបស់ប្រជាពលរដ្ឋភាគច្រើន ចំណែកព្រៃពិតប្រាកដនៅក្នុងទីតាំងគំរោងបានបង្ហាញថា មិនមានធនធានព្រៃឈើ ដែលមានតំលៃខាងផ្នែកសេដ្ឋកិច្ចទេ ធនធានព្រៃឈើគឺមានតែនៅលើភ្នំប៉ុណ្ណោះដែលជាព្រៃរេចរិលហើយភ្នំមួយចំនួនត្រូវបានកាប់រានយកដីធ្វើចំការជាបណ្តើរៗ។ ចំពោះប្រភេទដើមឈើដែលមាននៅក្នុងតំបន់គម្រោងមានដូចជាដើមធ្នង់ កំរៀង ស្តុង សុក្រំ ស្រឡៅ ដែលមានអង្កត់ផ្ចិតតូចជាង១០សង់ទីម៉ែត្រ។ទន្ទឹមនឹងនោះក៏មានការធ្វើអាជីវកម្មរ៉ែបែបអាណាធិបតេយ្យជាច្រើនផងដែរ ដែលមានភ្ជាប់រូបភាព និងចំណុចនិយាមការនៅក្នុង(ឧបសម្ព័ន្ធទី៣)។

ចំពោះពពួកមច្ឆាជាតិ ដែលមានវត្តមាននៅក្នុងតំបន់គម្រោងមានប្រមាណ ០៩ប្រភេទ បក្សីព្រៃមានប្រមាណ ០៩ប្រភេទ ថនិកសត្វអានប្រមាណ ០៦ប្រភេទ និងពពួកឧរង្គសត្វមានប្រមាណ ០៤ប្រភេទ។

ការសិក្សាធនធានសេដ្ឋកិច្ច-សង្គម គឺផ្អែកទៅលើសៀវភៅទិន្នន័យភូមិ-ឃុំឆ្នាំ២០១០ មានឃុំចំនួន០១ដែលពាក់ព័ន្ធនឹងទីតាំងគម្រោងគឺឃុំភ្នំព្រឹក ដែលមានភូមិចំនួន ០១ ដែលប៉ះពាល់នឹងទីតាំងគម្រោងគឺ ភូមិភ្នំព្រឹក។

មុខរបរដែលជាប្រភពផ្តល់ចំណូលសំខាន់របស់ ប្រជាជនភូមិភ្នំព្រឹកគឺការធ្វើចំការ (ដាំពោត ដំឡូងមី និងសណ្តែក)។ ក្រៅពីនោះគឺប្រជាជនប្រកបរបរស៊ីឈ្នួលគេតាមចំការ ដើម្បីរកចំណូលមកផ្គត់ផ្គង់ជីវភាពគ្រួសារ។

ប្រាក់ចំណូលរបស់ប្រជាជនមិនដូចគ្នាទេអាស្រ័យទៅតាមពេលវេលា ទំហំ និងប្រភេទមុខរបរដែលពួកគាត់កំពុងតែអនុវត្តន៍។ ប្រជាជនដែលរកចំណូលបានតិចជាងមួយលានរៀលក្នុងមួយខែមាន ៤៩% អ្នករកចំណូលបានចាប់ពីមួយលានដល់ពីរលានរៀលមាន ១៦% និងអ្នករកចំណូលបានលើសពីពីរលានរៀលមាន ៣៥%។

ចំណូលជាមធ្យមរបស់ប្រជាជនគឺ២.២១០.៧០០រៀល/ខែ។ទិន្នផលពោតជាមធ្យមទទួលបាន ៥តោន/ហ.ត ដែលមានតំលៃ ៨០០រៀល/គីឡូក្រាម ដំឡូងមីជាមធ្យមទទួលបាន ៣០តោន/ហ.ត ដំឡូងស្ងួតលក់បាន ៦០០រៀលក្នុងមួយគីឡូក្រាម ឯដំឡូងស្រស់លក់បាន ៣០០រៀល/គីឡូក្រាម។ សណ្តែកសៀងទិន្នផលជាមធ្យមទទួលបាន ២,៨ តោន/ហ.ត លក់បាន ៥.០០០រៀល/គីឡូក្រាម។

ការប្រើប្រាស់ដីៈ ដីដែលពាក់ព័ន្ធជាមួយប្រជាជនគឺមានចំនួន ២៩២ហិកតា ក្រុមហ៊ុននឹងធ្វើការចរចាដោះស្រាយជាមួយនឹងម្ចាស់ដី ដែលប៉ះពាល់ដោយផ្ទាល់ នៅពេលដែលដំណើរការជីកយករ៉ែលោហៈប៉ះដីរបស់ពួកគាត់។ចំពោះដីទ្រនាប់ដងអូរសងខាង ៩០ម៉ែត្រចំនួន ៥៩ហិកតា ក្រុមហ៊ុននឹងធ្វើការរក្សាទុកនូវផ្ទៃដីទាំងនោះ។

ការប្រើប្រាស់ទឹកៈ តាមការអង្កេត និងការសាកសួរជាមួយប្រជាជនក្នុងមូលដ្ឋានបានអោយដឹងថាប្រភពទឹកដែលមានក្នុង និង ជុំវិញតំបន់គំរោងគឺ ទឹកអណ្តូង និងទឹកអូរ។ ប្រភពទឹកសំខាន់សំរាប់ប្រើប្រាស់ប្រចាំថ្ងៃរបស់

Draft

ប្រជាជនគឺ ទឹកអណ្តូង និងទឹកភ្លៀង។ ឯទឹកអូរ គឺប្រើសំរាប់បោកគក់បន្តិចបន្តួច និងលាងសត្វពាហនៈ(អូរនេះរីងទឹកនៅរដូវប្រាំង)។

ការប្រើប្រាស់អគ្គិសនីៈ ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នេះបានទទួលបាននូវសេវាផ្គត់ផ្គង់អគ្គិសនីដែលមានប្រភពមកពីប្រទេស ថៃ ដែលមានតំលៃ ៩០០រៀល/គីឡូវ៉ាត់ម៉ោង។ ឯប្រភពថាមពលដែលប្រើប្រាស់ក្នុងការចំអិនអាហារគឺអុស ធ្យូង និងហ្គាស។

ការប្រើប្រាស់ផ្លូវថ្នល់ៈ ទីតាំងរបស់គំរោងស្ថិតនៅក្នុងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលមានចំងាយ ១៣៥ គីឡូម៉ែតពីទីរួមខេត្ត បាត់ដំបង និងមានចំងាយ ៧៥គីឡូម៉ែត្រពីខេត្តប៉ៃលិន(ផ្លូវជាតិលេខ៥៩)។ ផ្លូវមួយខ្សែនេះជាសរសៃឈាមសំរាប់តភ្ជាប់ពីតំបន់ភ្នំព្រឹកទៅកាន់ខេត្តប៉ៃលិន និងខេត្តបាត់ដំបង។ ផ្លូវនេះត្រូវបានប្រើប្រាស់សំរាប់ធ្វើចរាចរណ៍នូវកសិផល និងទំនិញផ្សេងៗរបស់ប្រជាពលរដ្ឋ ដែលចូលរួមចំណែកដល់ការអភិវឌ្ឍន៍មូលដ្ឋាន និងជួយលើកស្ទួយដល់កំរិតជីវភាពរបស់ប្រជាជន និងដើម្បីចូលរួមកាត់បន្ថយនូវភាពក្រីក្រផងដែរ។

សេវាសុខភាពៈ ឃុំបារាំងធ្លាក់មានប៉ុស្តិ៍សុខភាពមួយកន្លែង ពេលមានជំងឺប្រជាជនតែងតែទៅព្យាបាលនៅទីនោះ ឯឃុំភ្នំព្រឹកមិនមានប៉ុស្តិ៍សុខភាពទេ ដូច្នេះប្រជាពលរដ្ឋត្រូវទៅពិនិត្យនិងព្យាបាលជំងឺនៅមណ្ឌលសុខភាពរបស់ស្រុកភ្នំព្រឹក រឺក៏ទៅប៉ុស្តិ៍សុខភាពរបស់ឃុំបារាំងធ្លាក់។ ប៉ុន្តែបើសិនជាមានជំងឺធ្ងន់ធ្ងរ ប្រជាជនតែងតែនាំគ្នាទៅព្យាបាលនៅមន្ទីរពេទ្យខេត្តបាត់ដំបង រឺក៏ខេត្តប៉ៃលិន។ ពេលខ្លះប្រជាជន ក៏ទៅព្យាបាលជំងឺនៅពេទ្យឯកជនដោយសារមណ្ឌលសុខភាព រឺមន្ទីរពេទ្យរដ្ឋខ្លះមិនមានសំភារៈបរិក្ខារ និងថ្នាំពេទ្យគ្រប់គ្រាន់។

ប្រជាជនតែងតែជួបប្រទះជាញឹកញាប់នូវជំងឺដូចជា គ្រុនចាញ់ គ្រុនពោះវៀន និងមួយចំនួនតូចមានជំងឺរាគ និងផ្តាសាយជាដើម។ មូលហេតុដែលនាំអោយប្រជាជនជួបប្រទះនូវជំងឺ ដោយសារតែការរស់នៅគ្មានអនាម័យ ការបរិភោគទឹកមិនស្អាត ការបោះចោលសំរាម និងការបន្ទោរបង់ពាសវាលពាសកាល ។

ជនជាតិដើមភាគតិចៈ នៅក្នុងឃុំភ្នំព្រឹកនេះ មិនមានជនជាតិដើមភាគតិចរស់នៅទេ ព្រោះប្រជាជននៅក្នុងឃុំនេះសុទ្ធសឹងតែជាជនជាតិខ្មែរ ១០០ ភាគរយ។

ជំនឿសាសនា និងទីសក្ការៈបូជាៈ នៅក្នុងឃុំភ្នំព្រឹកមានវត្តមួយ ដែលមានឈ្មោះថា **វត្តគិរីរម្យសន្តិភាព** ហៅវត្តអូរចោទ សំរាប់ឲ្យប្រជាពលរដ្ឋគោរពបូជា និងប្រារព្ធពិធីបុណ្យបែបសាសនាផ្សេងៗដូចជា ចូលឆ្នាំថ្មី ភ្ជុំបិណ្ឌ កឋិនទាន ។ល។

តំបន់ទេសចរណ៍ៈ ឃុំអូររំដួលមានរមណីយដ្ឋានទឹកធ្លាក់មួយកន្លែង ដែលមានឈ្មោះថា **ទឹកធ្លាក់ភ្នំ ៥៣**។ ទឹកធ្លាក់នេះ មិនសូវមានប្រជាជនទៅលេងកំសាន្តទេ លើកលែងតែមានពិធីបុណ្យធំៗដូចជា ចូលឆ្នាំជាដើមទើបមានគេទៅលេង។ នៅរដូវប្រាំងទឹកធ្លាក់នេះមិនសូវមានទឹកទេ។

បញ្ជាក់ៈ ក្នុងឃុំភ្នំព្រឹកមិនមានសហគមន៍ព្រៃឈើ និងសំណង់ប្រាសាទបុរាណទេ។

## ៥. ការពិគ្រោះយោបល់សាធារណៈ

ការពិគ្រោះយោបល់ជាមួយនឹងសាធារណៈជន ដែលទាក់ទងនឹងគំរោងវិនិយោគអាជីវកម្មរ៉ែលោហៈរួមមាន តំណាងសាលាខេត្តបាត់ដំបង មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល មន្ទីរបរិស្ថាន មន្ទីរកសិកម្ម មន្ទីររៀបចំដែនដី

Draft

នគរូបនីយកម្ម សំណង់ និងសុរិយោដី មន្ទីរធនធានទឹក និងឧតុនិយម ខណ្ឌរដ្ឋបាលព្រៃឈើ ខណ្ឌរដ្ឋបាលជលផល អាជ្ញាធរស្រុកភ្នំព្រឹក និងអាជ្ញាធរឃុំភ្នំព្រឹក (ភូមិភ្នំព្រឹក និងភូមិបេងស្អាត)។

ជាលទ្ធផល តំណាងអាជ្ញាធរពាក់ព័ន្ធ និងមន្ទីរពាក់ព័ន្ធមានការឯកភាព លើគម្រោងវិនិយោគនេះ។

# ៦. ហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ

## ហេតុប៉ះពាល់បរិស្ថាន

ក្នុងដំណាក់កាលដែលមានហេតុប៉ះពាល់បរិស្ថាន និងសង្គមខ្លាំងជាងគេគឺដំណាក់កាលឈូសឆាយ និងសាងសង់ដោយសារសកម្មភាពមួយចំនួនដូចជាការសាងសង់ផ្លូវចូលក្នុងការដ្ឋាន ការសាងសង់រោងចក្រ សាងសង់ឃ្លាំង សាងសង់មណ្ឌលសុខភាព សាងសង់ការិយាល័យ អាគារស្នាក់នៅរបស់បុគ្គលិក និងកម្មករ ការជីករណ្តៅរ៉ែ ។ល។សកម្មភាពការងារទាំងនេះនឹងអាចបង្កអោយមានការប៉ះពាល់ដល់បរិស្ថានអវិជ្ជមានសំខាន់ៗគឺ

-ការប្រែប្រួលសណ្ឋានដីក្នុងទីតាំងគម្រោងដោយសារសកម្មភាពឈូសឆាយដី និងសាងសង់ ផ្លូវចូល ក្នុងការដ្ឋាន។ល។

-ការហូរច្រោះដីដោយសារនៅទីតាំងគម្រោងជាតំបន់ភ្នំតាមរយៈការឈូសឆាយដី

-ការប្រែប្រួលប្រព័ន្ធធារាសាស្ត្រ និងប៉ះពាល់ទឹកក្រោមដី និងលើដីដូចជាអូរព្រំដែន និងប៉ះពាល់ ដល់ជីវចម្រុះក្នុងទឹក

-ប៉ះពាល់ដល់ធនធានព្រៃឈើតិចតួច ព្រោះធនធានព្រៃឈើក្នុងទីតាំងគម្រោងគឺមានតែនៅលើភ្នំប៉ុណ្ណោះ

-សកម្មភាពរបស់គម្រោងនឹងប៉ះពាល់ដល់ការប្រើប្រាស់ទឹក សុខភាព មុខរបរ ប្រពៃណី ជំនឿ វប្បធម៌ និងការប្រើប្រាស់ផ្លូវគមនាគមន៍របស់ប្រជាពលរដ្ឋនៅក្នុងតំបន់។

## វិធានការកាត់បន្ថយ

-ក្រុមហ៊ុននឹងធ្វើការឈូសឆាយពង្រាបដី ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធនានាក្នុងតំបន់គម្រោង ដែលដូចមានចែងក្នុងផែនការមេរបស់ក្រុមហ៊ុនដោយមានការត្រួតពិនិត្យ និងវាយតំលៃយ៉ាងត្រឹមត្រូវពីមន្ត្រីមន្ទីរពាក់ព័ន្ធពិតជាអាចកាត់បន្ថយ ឬបញ្ចៀសនូវការប្រែប្រួលសណ្ឋានដីតំបន់គម្រោងអោយស្ថិតនៅកំរិតអប្បបរមា។

-ក្រុមហ៊ុននឹងបិទហាឧសកម្មភាពឈូលឆាយខ្លាំងនៅរដូវវស្សា។

-ក្រុមហ៊ុននឹងឈូសឆាយដីពង្រាបដីសំរាប់សាងសង់ ដោយគោរពតាមលក្ខណៈទម្រង់ប្រភេទដី និងបែបបទការអនុវត្តន៍របស់ក្រុមហ៊ុន ដើម្បីកាត់បន្ថយការហូរច្រោះដីដោយសារសកម្មភាពសាងសង់នានារបស់គម្រោង។

-មានផែនការគ្រប់គ្រងសំណល់រឹង-រាវគ្រប់ប្រភេទអោយបានល្អប្រសើរ គឺជីករណ្តៅ ដែលមានលក្ខណៈបច្ចេកទេសសំរាប់ទុកដាក់សំណល់រឹងដោយលប់ដីជាប្រចាំនិងសាងសង់បង្គន់អនាម័យដែលមានអាងស្តុកសំណល់រាវឲ្យបានត្រឹមត្រូវជៀសវាងការបង្ហូរសំណល់រាវឬចោលសំណល់រឹង/សំរាមទៅតាមទីសាធារណៈ។

-ធ្វើការណែនាំ និងអប់រំដល់បុគ្គលិក-កម្មករ ដោយហាមប្រាមមិនអោយមានការបោះចោលសំរាមពាសវាលពាសកាល ឬបង្ហូរសំណល់រាវទៅទីសាធារណៈឡើយ។

-ក្រុមហ៊ុននឹងធ្វើការរក្សាទុកនូវដីទ្រនាប់ដងអូរសងខាង ១០០ម៉ែត្រចំនួន ៥៤ហិកតា។

-កំណត់ពេលវេលាធ្វើការច្បាស់លាស់ ដូចជាធ្វើការតែនៅពេលថ្ងៃ (ម៉ោងចាប់ផ្តើម៧.៣០ ទៅ ១១.៣០នាទី និងល្ងាចម៉ោង១.៣០ ទៅ ៥.៣០នាទី)។

-ក្រុមហ៊ុនត្រូវរួសរាន់លប់ និងដាំដើមឈើ (ពូជក្នុងស្រុក)លើគំរបដីឡើងវិញភ្លាមៗបន្ទាប់ពីយករ៉ែរួច។

-ក្រុមហ៊ុននឹងធ្វើការអប់រំណែនាំដល់បុគ្គលិក-កម្មករទាំងអស់របស់គម្រោងអោយមានការប្រុងប្រយ័ត្នចំពោះការបង្កាត់ភ្លើងសំរាប់គោលបំណងផ្សេងៗ និងការចោលកន្ទុយបារី ដើម្បីជៀសវាងភ្លើងឆេះព្រៃ ហើយត្រូវរាយការណ៍ដល់អាជ្ញាធរមូលដ្ឋាននៅពេលខ្លួនប្រទះឃើញភ្លើងឆេះព្រៃក្នុងតំបន់គម្រោងដើម្បីធ្វើការទប់ស្កាត់អោយបានល្អទាន់ពេលវេលា។

## ៧. ផែនការគ្រប់គ្រងបរិស្ថាន

ចំពោះការអនុវត្តន៍ផែនការគ្រប់គ្រងបរិស្ថាន ជាភារកិច្ចរបស់ក្រុមហ៊ុនដែលត្រូវអនុវត្តន៍ផ្ទាល់ ដោយមានផ្នែក ក្រុម ឬការិយាល័យបរិស្ថានរបស់ក្រុមហ៊ុន ដើម្បីធ្វើការត្រួតពិនិត្យបញ្ហាបរិស្ថានដែលកើតមានឡើងនៅក្នុង និងជុំវិញទីតាំងគម្រោងវិនិយោគអាជីវកម្មរ៉ែលោហៈ។ក្រុមត្រួតពិនិត្យរបស់ស្ថាប័នពាក់ព័ន្ធមានសិទ្ធិស្របច្បាប់ដើម្បីចុះត្រួតពិនិត្យពីលើក្រុមហ៊ុនផ្ទាល់នៅគ្រប់ពេលទាំងអស់។ ជាគោលការណ៍ក្រុមហ៊ុនត្រួតពិនិត្យ និងការឃ្លាំមើលវិធានការការពារបរិស្ថានគឺស្ថិតនៅក្រោមការត្រួតពិនិត្យ និងតាមដានពីក្រសួងបរិស្ថាន។

កម្មវិធីអង្កេតតាមដានត្រួតពិនិត្យ និងការអនុវត្តន៍វិធានការការពារបរិស្ថាន (វិធានការកាត់បន្ថយការប៉ះពាល់បរិស្ថានដែលបានចែងក្នុងជំពូកទី៦ បញ្ជាក់អំពីកិច្ចការដែលត្រូវអង្កេតតាមដាន និងត្រួតពិនិត្យគម្រោងផងដែរ ម្យ៉ាងវិញទៀតកម្មវិធីនេះនឹងប្រមើលឃ្លាំមើលការអនុវត្តន៍គម្រោងដោយម្ចាស់គម្រោងនៅក្នុងការអនុវត្តន៍គម្រោង។

ក្រុមហ៊ុននឹងត្រួតពិនិត្យមើលផែនការគ្រប់គ្រងបរិស្ថាន និងត្រូវសរសេររបាយការណ៍ពីការពិនិត្យនេះទៅក្រសួងបរិស្ថានរៀងរាល់ ០៦ខែម្តង។ លើសពីនេះទៀត ម្ចាស់គម្រោងត្រូវយកចិត្តទុកដាក់អោយបានហ្មត់ចត់លើការអនុវត្តន៍ផែនការគ្រប់គ្រងបរិស្ថានដោយមានមូលនិធិបរិស្ថាន និងសង្គមសំរាប់គាំទ្រដល់កិច្ចការពារបរិស្ថាន និងការអភិវឌ្ឍន៍ភូមិឃុំដែលពាក់ព័ន្ធ។លើសពីនេះទៀត ម្ចាស់គម្រោងនឹងរៀបចំមានវគ្គបំពាក់បំប៉នដល់បុគ្គលិក និងកម្មករដែលជានិយោជិកអំពីការងារបរិស្ថាន។

## ៨. ការវិភាគសេដ្ឋកិច្ច និងតំលៃបរិស្ថាន

ចំណូលប្រចាំឆ្នាំ ដែលទទួលបានពីការធ្វើចំការដែលមានភាគរយច្រើនជាងមុខរបរដទៃ (៨០ភាគរយ) ជាពិសេសសំរាប់ប្រជាជនរស់នៅក្នុងភូមិភ្នំព្រឹក និងប្រជាជនរស់នៅខាងលើ និងខាងក្រោមប្រព័ន្ធទឹកដែលហូរកាត់តំបន់តំរោងនឹងត្រូវបានគណនាដោយផ្អែកលើចំនួនប្រជាជននិងតំលៃទីផ្សារក្នុងស្រុករបស់ផលិតផលកសិកម្ម។ តាមទិដ្ឋភាពបរិស្ថាន ក្រុមសិក្សាអាចកំណត់បានថាប្រជាពលរដ្ឋ ដែលរស់នៅតាមប្រភពទឹកខាងក្រោម នៅតែអាចបន្តការប្រើប្រាស់ទឹករបស់ពួកគេ ទោះបីពួកគាត់មួយចំនួនរងនូវផលប៉ះពាល់ពីអាជីវកម្មរ៉ែមាសក្តី។

ចំនូលប្រចាំឆ្នាំជាមធ្យម ដែលទទួលបានពីការដាំពោត ដំឡូងមី និងសណ្តែក របស់ប្រជាពលរដ្ឋនៅភូមិភ្នំព្រឹកត្រូវបាន គណនាដោយផ្អែកលើទិន្នផលជាមធ្យមប្រចាំឆ្នាំ របស់ និងតំលៃទីផ្សារក្នុងស្រុកជាមធ្យម។

តាមការសិក្សា បង្ហាញថាចំណូលជាមធ្យមរបស់ប្រជាពលរដ្ឋពីការធ្វើចំការ (∑Agr)គឺ ៨១០.៧០០រៀល/ខែ ឬ ២០២,៦៧៥ដុល្លារក្នុង១ខែស្មើនឹង២.៨៣២,១ដុល្លារ/ឆ្នាំ។

យោងតាមផែនទីគំរបព្រៃឆ្នាំ២០០៦ របស់រដ្ឋបាលព្រៃឈើបង្ហាញថា នៅក្នុងតំបន់គំរោងមានតែគំរបព្រៃស្រោង និងដីគ្មានគំរបព្រៃប៉ុណ្ណោះ។ ដីគ្មានគំរបព្រៃភាគច្រើនជាដីចំការ របស់ប្រជាពលរដ្ឋដែលត្រូវបានសិក្សាពីតំលៃសេដ្ឋកិច្ចនៅខាងលើរួចរាល់ហើយ។ ដូចនេះការវិភាគធនធានធម្មជាតិ ជាតំលៃបរិស្ថាននេះ គឺធ្វើឡើងតែលើតំបន់ដែលមានព្រៃស្រោងតែប៉ុណ្ណោះ ដែលមានផ្ទៃសរុប ១០៨ហិចតា (*ធនធានគំរបព្រៃឈើកម្ពុជាឆ្នាំ ២០០៦*)។

ផ្អែកតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវស្តីពីការវិភាគសេដ្ឋកិច្ចពីការគ្រប់គ្រងធនធានព្រៃឈើអោយមាននិរន្តភាពក្នុងប្រទេសកម្ពុជា ដែលបានបោះពុម្ពនៅ ខែធ្នូ ឆ្នាំ២០១២ របស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នៃកម្ពុជា(ស៊ី ឌី អ័រ អាយ) បានបង្ហាញថា តំលៃសេដ្ឋកិច្ចរបស់ព្រៃស្រោងគឺ ៣៧៥ដុល្លាសហរដ្ឋអាមេរិក សំរាប់មួយហិចតា ក្នុងរយៈពេលមួយឆ្នាំ។

ដូចនេះ តំលៃសេដ្ឋកិច្ចសរុបនៃការគ្រប់គ្រងធនធានព្រៃឈើអោយមាននិរន្តភាព (∑Fr) ស្មើនឹង ផ្ទៃដីនៃព្រៃស្រោងសរុប គុណនឹង តំលៃសេដ្ឋកិច្ចរបស់ព្រៃស្រោងសំរាប់មួយហិចតា ក្នុងរយៈពេលមួយឆ្នាំ។

តាមការសំភាសន៍ជាមួយប្រជាពលរដ្ឋរបស់ក្រុមសិក្សាបានបង្ហាញអោយឃើញថា ពពួកមច្ឆាជាតិដែលមានវត្តមាននៅក្នុងតំបន់គំរោងមានប្រមាណ០៩ប្រភេទ (មានលំអិតក្នុងជំពូក៤)។ ដោយសារតែទឹកអូររងនូវការបំពុលពីការរែងរ៉ែជាលក្ខណៈគ្រួសាររបស់ប្រជាជន ទើបធ្វើអោយមានការបាត់បង់ប្រភេទត្រីជាច្រើន។ ហើយការសិក្សារ ក៏បានបង្ហាញថាមិនមាន គ្រួសារណាប្រកបរបរនេសាទដែរ។ ជារួម មានគ្រួសារតិចតួចប៉ុណ្ណោះ ដែលរកត្រីតាមអូរនេះសំរាប់ការបរិភោគប្រចាំថ្ងៃពេលខ្លះតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត ត្រីរស់នៅក្នុងអូរ ដែលទទួលរងការបំពុលពីការរែងរ៉ែមាសអាណាធិបតេយ្យ ក៏មិនសមស្រប សំរាប់ប្រជាពលរដ្ឋយកទៅបរិភោគដែរ។ ជាទូទៅបរិមាណត្រីជាមធ្យមដែលប្រពលរដ្ឋរកបានក្នុងអូរគឺ ០,៣៥គីឡូក្រាមក្នុង១ថ្ងៃ ឬ១២៧,៧៥គីឡូក្រាមក្នុង១ឆ្នាំ។

ផ្អែកតាមការពិគ្រោះយោបល់សាធារណៈ . វិធានការណ៍កាត់បន្ថយ និងគំរូវការពលកម្មសំរាប់ចាប់ផ្តើមគំរោងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទូទៅក្នុងមូលដ្ឋាននឹងបានប្រសើរឡើង។ ជាក់ស្តែង ក្រុមហ៊ុន ក៏មានបន្ថែមកម្មវិធីមួយចំនួនទៀត ដើម្បីជួយដល់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋក្នុងតំបន់គំរោង រួមមាន: (i) ការត្រួតពិនិត្យគុណភាពទឹកជាប្រចាំដើម្បីធ្វើអោយមានកំណើនមច្ឆាជាតិឡើងវិញ និងដើម្បីអោយប្រជាពលរដ្ឋអាចប្រើប្រាស់បាន (ii) បង្ហាត់បង្រៀនពីបច្ចេកទេសរុករករ៉ែ ដែលមានផលប៉ះពាល់ដល់ បរិស្ថានកំរិតតិច ឬមិនមានផលប៉ះពាល់ (iii) ពេលជ្រើសរើសកម្មករ ក្រុមហ៊ុននឹងផ្តល់អាទិភាពដល់ប្រជាពលរដ្ឋក្នុងតំបន់គំរោងជាមុន (iv) ក្រុមហ៊ុននឹង ធ្វើការដាំដុះកូនឈើតាមតំបន់ ដែលធ្វើអាជីវកម្មរួច ឬតំបន់ដែលងាយហូរច្រោះ (v) សកម្មភាពមួយចំនួនទៀតទាក់ទងការសាងសង់គំរោង ប្រតិបត្តិការគំរោង ដើម្បីកែលំអរជីវភាពប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

ក.បរិស្ថាន

មូលនិធិសំរាប់អភិវឌ្ឍសហគមន៍ក្នុងក្នុងរយៈពេល១ឆ្នាំ: ១៥.០០០ដុល្លារ

មូលនិធិសំរាប់ស្តារបរិស្ថានក្នុងរយៈពេល១ឆ្នាំ: ១៥.០០០ដុល្លារ

∑Env = ១៥.០០០ដុល្លារ + ១៥.០០០ដុល្លារ = ៣០.០០០ដុល្លារ

ខ.សេដ្ឋកិច្ច

ថ្លៃឈ្នួលលើផ្ទៃក្រលាសំរាប់ដីសម្បទានក្នុងរយៈពេល១ឆ្នាំ: ៣.០០០ដុល្លារ

ថ្លៃឈ្នួលលើផ្ទៃក្រលាសំរាប់ដីធ្វើអាជីវកម្មក្នុងរយៈពេល១ឆ្នាំ: ១.៦០០ដុល្លារ

ពន្ធលើប្រាក់ចំណេញ: ៨.៥៣១.៧១០ដុល្លារ

ពន្ធអាករផ្សេងៗ និងប៉ាតង់:២០.០០០ដុល្លារ

ថ្លៃសួយសារ: ១.៧១០.០០០ដុល្លារ

VAT ១០% នៃការនាំចូលសម្ភារៈ និងគ្រឿងចក្រសំរាប់ផលិតៈ ៥៥.៤៧៦ដុល្លារ

$\sum Eco$ = ៣.០០០ដុល្លារ + ១.៦០០ដុល្លារ + ៨.៥៣១.៧១០ដុល្លារ + ២០.០០០ដុល្លារ + ១.៧១០.០០០ដុល្លារ + ៥៥.៤៧៦ដុល្លារ = **១០.៣២១.៧៨៦ដុល្លារ**

គ.សង្គម

ស្ពានផ្លូវមកកាន់តំបន់ការដ្ឋានដែលមានប្រវែង០៣គម ជាមួយនឹងតំលៃ: ៥០.០០០ដុល្លារ

បង្កើតការងារ និងការចំណាយលើកំលាំងពលកម្មក្នុងរយៈពេល១ឆ្នាំ: ១៧៦.៤០០ដុល្លារ

$\sum Soc$ = ៥០.០០០ដុល្លារ + ១៧៦.៤០០ដុល្លារ = **២២៦.៤០០ដុល្លារ**

$\sum(Agr, Fr, Fp, Fi)$ = $\sum Agr$ (ដុល្លារ) + $\sum Fr$ (ដុល្លារ) + $\sum Fp$ (ដុល្លារ) + $\sum Fi$ (ដុល្លារ)

= ៤៦៨.៥៣១,១ + ៣៩.០០០ + 0 + ៦១.០០០,៦៣

= ៥៦៨.៥៣១,៧៣ដុល្លារ

$\sum(Env, Eco, Soc)$ = $\sum Env$(ដុល្លារ) + $\sum Eco$ (ដុល្លារ) + $\sum Soc$ (ដុល្លារ)

= ៣០.០០០ + ១០.៣២១.៧៨៦ + ២២៦.៤០០

= ១០.៥៧៨.១៨៦ដុល្លារ

លទ្ធផលខាងលើបង្ហាញថា $\sum(Env, Eco, Soc) > \sum(Agr, Fr, Fp, Fi)$ ឬផលវិជ្ជមានធំជាងផលអវិជ្ជមាននៅពេលដែល គម្រោងធ្វើអាជីវកម្មរ៉ែលោហៈរបស់ ក្រុមហ៊ុន ភូ យ៉ាំង ចាប់ដំណើរការ ដែលអាចស្រូបយកកំលាំងពលកម្មក្នុងន័យធ្វើអោយប្រសើរឡើងនូវជីវភាព របស់ប្រជាពលរដ្ឋក្នុងតំបន់ ការបង្កើនចំណូលជាតិ តាមរយៈការបង់ពន្ធ ការបង្កើនលទ្ធភាពក្នុងកិច្ចការពារបរិស្ថានតាមរយៈមូលនិធិ និងស្ពានផ្លូវសំរាប់ប្រើប្រាស់សំរាប់ការដឹកជញ្ជូនរបស់ក្រុមហ៊ុន ក៏ដូចជាបំរើដល់ប្រយោជន៍សាធារណៈដល់ប្រជាពលរដ្ឋក្នុង ភូមិ-ឃុំ ដោយស្របតាមគោលនយោបាយរាជរដ្ឋាភិបាល។

## ៩ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

តាមរយៈសេចក្តីសន្និដ្ឋាន ក្រុមហ៊ុននឹងរិះរកអោយអស់លទ្ធភាពនូវវិធានការការពារបរិស្ថាននៅក្នុងនិងជុំវិញតំបន់អាជីវកម្មរ៉ែលោហៈដើម្បីជៀសវាងមានការប៉ះពាល់បរិស្ថាន និងសង្គមធ្ងន់ធ្ងរ។ ជាអនុសាសន៍ ក្រុមហ៊ុនត្រូវខិតខំធ្វើកិច្ចសហការជាមួយក្រសួង/ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដើម្បីរកដំណោះស្រាយនូវបញ្ហា ដែលកើតមានឡើងជាមួយប្រជាពលរដ្ឋនៅក្នុងតំបន់គម្រោង និងដំណោះស្រាយផ្សេងៗទៀត។ លើសពីនេះទៀត ក្រុមហ៊ុនត្រូវអនុវត្តន៍អោយបានម៉ត់ចត់នូវផែនការគ្រប់គ្រងបរិស្ថាន ដើម្បីធានានូវការអភិវឌ្ឍន៍ប្រកបដោយធនធានរ៉ែអោយមាននិរន្តភាពបរិស្ថាន។

Draft